**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តតាកែវ**
លេខ៤៤៩...ស.ជ.ណ

ថ្ងៃសុក្រ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
តាកែវ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងមោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

- យោងអនុក្រឹត្យលេខ: ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ។
- យោងអនុក្រឹត្យលេខ:១២២ អនក្រ/បក ចុះថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា ៦ មាត្រា ៧ និង មាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ។
- យោងលិខិតលេខ:៣២៤ ដនសស / តក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តតាកែវ និងបានការឯកភាពពីលោកប្រធានគណៈកម្មការរដ្ឋបាល។

រដ្ឋបាលខេត្តតាកែវ មានកិត្តិយស សូមជម្រាបជូនម្ចាស់ដីនៃក្បាលដីនៅតំបន់វិនិច្ឆ័យភូមិ សេដ្ឋី និងភូមិពន្ទង ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ឱ្យបានជ្រាបថា ៖ យោងតាមអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីក្រោមដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវនឹងធ្វើការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប័ណ្ណកម្មសិទ្ធិ)ជូនដល់ម្ចាស់ក្បាលដីដែលនៅក្នុងភូមិ សេដ្ឋី និងភូមិពន្ទង ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ចាប់ពីថ្ងៃព្រហស្បតិ៍ ៩ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ដល់ថ្ងៃសុក្រ ១០ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ទីតាំងចែកប័ណ្ណស្ថិតនៅស្នាក់ការភូមិនីមួយៗ។

ចំពោះប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ( ប័ណ្ណស្លាបមាន់ ) ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដីកន្លងមក ក្នុងតំបន់នេះនឹងត្រូវអស់សុពលភាពតាមផ្លូវច្បាប់ចាប់ពីថ្ងៃចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើនេះតទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមម្ចាស់ក្បាលដីស្ថិតនៅទីតាំងខាងលើដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុកន្លងមក មេត្តា យកប័ណ្ណទាំងនោះមកប្រគល់ឱ្យមន្ត្រីរដ្ឋបាលសុរិយោដី ដើម្បីទទួលយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីជំនួសវិញដែលនឹងត្រូវប្រគល់ជូនដោយមន្ត្រីរដ្ឋបាលសុរិយោដីនៅភូមិសេដ្ឋី និងភូមិពន្ទង ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ចាប់ពីថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៣ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ជាកំហិត ។

ចំពោះម្ចាស់បំណុលដែលបានទទួលបញ្ចាំ ឬ ហ៊ីប៉ូតែកពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់វិនិច្ឆ័យខាងលើ សូម យកប័ណ្ណទាំងនោះមកជូនមន្ត្រីរដ្ឋបាលសុរិយោដីធ្វើនិយ័តកម្ម ដើម្បីធានាប្រាក់របស់លោកអ្នក ។

**អភិបាលខេត្ត**

**អ៊ូច ភា**

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាខេត្ត
"ដើម្បីជូនជ្រាបជាព័ត៌មាន"
- គម្រោងអនុវិស័យរដ្ឋបាលដីធ្លី
- មន្ទីរ ដនសស តាកែវ
- រដ្ឋបាលស្រុកព្រៃកប្បាស
- ការិយាល័យ ដនសក ស្រុកព្រៃកប្បាស
"ដើម្បីជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ